# ទសព្រាហ្មណជាតក



ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធ**អសទិសទាន**[១] បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **រាជា អវោច វិធុរំ** ដូច្នេះជាដើម ។

---

១. ទានដែលឥតមានទានដទៃណាមួយប្រដូចបាន គឺទានដែលព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជានុញ្ញាតឲ្យប្រជានុរាស្ត្រមានសិទ្ធិធ្វើប្រណាំងនឹងព្រះអង្គ ។ អសទិសទាននេះក្នុងកាលនៃព្រះពុទ្ធមួយព្រះអង្គ មានត្រឹមតែម្តងគត់ ឥតដែលមានពីរដងឡើយ, មានន័យថា គឺព្រះរាជាទ្រង់មានព្រះរាជបញ្ជាឲ្យចាត់ចែងធ្វើទក្ខិណាទានចំពោះព្រះភិក្ខុសង្ឃច្រើនអង្គ មានព្រះពុទ្ធជាប្រធាន, ទ្រង់ធ្វើក្នុងមួយថ្ងៃ, ប្រជានុរាស្ត្រធ្វើមួយថ្ងៃ, ធ្វើបែបនេះរៀងរាល់ថ្ងៃតៗគ្នា, ព្រះរាជានិងប្រជានុរាស្ត្រចេះតែធ្វើឲ្យមានរបៀបនិងទេយ្យទានប្លែកលើសពីគ្នា, ធ្វើទានបែបនេះយូរថ្ងៃណាស់, ចេះតែឈ្នះគ្នាម្តងម្នាក់ គឺជួនឈ្នះគ្នាដោយរបៀប ជួនឈ្នះគ្នាដោយទេយ្យទាន, លុះថ្ងៃចុងក្រោយបំផុត ព្រះរាជាទ្រង់ឈ្នះ ព្រោះប្រជានុរាស្ត្រទាល់គំនិតពុំអាចលែលកឲ្យឈ្នះព្រះអង្គបានឡើយ, ក៏ចប់ស្រេចត្រឹមប៉ុណ្ណោះឯង : *ក្នុងកាលនៃព្រះសក្យមុនីសម្ពុទ្ធ ព្រះបាទបសេនទិកោសល ព្រះរាជាក្រុងសាវត្ថីទ្រង់ធ្វើអសទិសទានឈ្នះប្រជានុរាស្ត្រ ដោយសារមធ្យោបាយឈ្លាសវៃនៃព្រះអគ្គមហេសីទ្រង់ព្រះនាមមល្លិកាទេវី* (ចាកវចនាក្រុមសម្តេចជួន ណាត)។

អសទិសទាននោះមានពិស្ដារក្នុង**អាទិត្តជាតក** ក្នុងអដ្ឋកនិបាត ។ បានឮមកថា ព្រះរាជាកាលថ្វាយទាន ធ្វើព្រះសាស្ដាឲ្យជាប្រធាន ជ្រើសរើសភិក្ខុ ៥០០ រូប កាន់យកហើយ ឲ្យទានដល់មហាខីណាស្រពប៉ុណ្ណោះ ។ លំដាប់នោះ កាលភិក្ខុទាំងឡាយពោលគុណកថារបស់ព្រះរាជា បានញុំាងកថាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ ព្រះរាជាកាលឲ្យអសទិសទាន បានជ្រើសរើស ហើយឲ្យទានក្នុងឋានដែលមានផលធំ ។ ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយរឿងអ្វី កាលភិក្ខុទាំងឡាយពោលថា ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនជាអស្ចារ្យទេ កាលស្ដេចកោសលរាជ ដែលជាឧបដ្ឋាករបស់ព្រះពុទ្ធប្រាកដដូចជាតថាគត ជ្រើសរើសហើយ ថ្វាយទាននោះ បោរាណបណ្ឌិតទាំងឡាយ សូម្បីក្នុងកាលព្រះពុទ្ធមិនកើតឡើង ក៏បានជ្រើសរើស ហើយឲ្យទានដែរ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសម្ដែងថា

ក្នុងអតីតកាល កាលព្រះរាជាព្រះនាម **កោរព្យយុធិដ្ឋិលគោត្ត** សោយរាជសម្បត្តិក្នុងឥន្ទបត្តនគរ ក្នុងដែនកុរុរដ្ឋ ។ អាមាត្យរបស់ព្រះរាជានោះ មានឈ្មោះថា **វិធុរៈ** តែងប្រៀនប្រដៅនូវអត្ថ និងធម៌ ។ ព្រះរាជាបានញុំាងសកលជម្ពូទ្វីបឲ្យកម្រើក ទ្រង់ថ្វាយមហាទាន ។ បណ្ដាមនុស្សដែលទទួលទាននោះ ហើយបរិភោគ មិនមានអ្នករក្សាសីល ៥ សូម្បីតែម្នាក់ មនុស្សទាំងអស់នោះជាបុគ្គលទ្រុស្ដសីល (ព្រោះហេតុនោះ) ទាននោះទើបមិនបានញុំាងព្រះហឫទ័យរបស់ព្រះរាជាឲ្យត្រេកអរ ។ ព្រះរាជាគិតថា ទានដែលជ្រើសរើសហើយ នឹងមានផលច្រើន ដូច្នេះទ្រង់មានសេចក្ដីប្រាថ្នាឲ្យទានដល់អ្នកមានសីល ស្ដេចបានគិតទៀតថា យើងនឹងពិភាក្សាជាមួយវិធុរបណ្ឌិត ។ ព្រះរាជាកាលវិធុរបណ្ឌិតមកកាន់ទីបម្រើ បានឲ្យអង្គុយលើអាសនៈហើយ ទើបត្រាស់សួរបញ្ហា ។

*ព្រះសាស្ដាកាលប្រកាសសេចក្ដីនោះ ទើបត្រាស់កន្ទះគាថា*

**រាជា អវោច វិធុរំ, ធម្មកាមោ យុធិដ្ឋិលោ"តិ;**

*ព្រះរាជាជាយុធិដ្ឋិលគោត្រ ព្រះអង្គប្រាថ្នានូវធម៌បានត្រាស់នឹងអាមាត្យឈ្មោះវិធូរៈ ។*

*ពាក្យតទៅនេះ ជាព្រះតម្រាស់របស់ព្រះរាជា និងពាក្យឆ្លើយរបស់វិធុរបណ្ឌិត ៖*

ព្រះរាជាត្រាស់ថា

ព្រាហ្មណេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

*ម្នាលវិធូរៈអ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដែលជាអ្នកមានសីលជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ កុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហាប្ផលំ។

*ជាអ្នកវៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ទក្ខិណាទានដែលគេ ឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន ម្នាលសម្លាញ់ យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

អាមាត្រឈ្មោះវិធូរៈក្រាបទូលថា

ទុល្លភា ព្រាហ្មណា ទេវ, សីលវន្តោ ពហុស្សុតា;
វិរតា មេថុនា ធម្មា, យេ តេ កុញ្ជេយ្យុ ភោជនំ។

*បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគនូវភោជនរបស់ព្រះអង្គ គេរកបានដោយក្រ ។*

ទស ខលុ មហារាជ, យា តា ព្រាហ្មណជាតិយោ;
តេសំ វិភង្គំ វិចយំ, វិត្ថារេន សុណោហិ មេ។

បពិត្រមហារាជ ឮថា ជាតិព្រាហ្មណ៍ទាំងឡាយណាមាន ១០ យ៉ាង សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ នូវការចែករំលែក និងការពិនិត្យពិច័យ នូវព្រាហ្មណ៍ទាំងនោះ តាមប្រាជ្ញារបស់ទូលព្រះបង្គំជាខ្ញុំ ដោយពិស្ដារចុះ ។

បសិព្ពកេ គហេត្វាន, បុណ្ណេ មូលស្ស សំវុតេ;
ឱសធិកាយោ គន្ថេន្តិ, ន្ហាបយន្តិ ជបន្តិ ច។

ព្រាហ្មណ៍ទាំងឡាយ កាន់ការុងទាំងឡាយ ដែលពេញដោយឫសឈើ ចងមាត់ជិត ហើយតែងក្បួនថ្នាំទាំងឡាយផង ផ្ងូតទឹកឲ្យគេផង សែកនូវ (ភូតវិជ្ជា[១]) ផង ។

តិកិច្ឆកសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

បពិត្រព្រះរាជា ឯព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយពេទ្យ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ទូលព្រះបង្គំជាខ្ញុំ បានក្រាបទូលចំពោះព្រះអង្គរួចហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍ ប្រាកដដូច្នោះឬ ?

ព្រះចាងកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

---

១. វិជ្ជាចាប់ខ្មោចវិជ្ជាចាប់ខ្មោច ។

*ពួកព្រាហ្មណ៍ទាំងនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងនោះ គេមិនហៅថា ព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

វិធុរបណ្ឌិតក្រាបទូលថា

កិង្កិណិកាយោ គហេត្វា, ឃោសេន្តិ បុរតោបិ តេ;
បេសនានិបិ គច្ឆន្តិ, រថចរិយាសុ សិក្ខរេ។

*ព្រាហ្មណ៍ទាំងឡាយនោះ កាន់ឃ្មោះទាំងឡាយហើយឃោស្នាឮដំខាងមុខ (នៃស្តេចនិងអាមាត្រ) ក៏មាន ទៅកាន់ទីសម្រាប់បម្រើគេក៏មាន សិក្សាខាងសិល្បរថក៏មាន ។*

បរិចារកសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយជនអ្នកបម្រើ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះចាងហោរព្យាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

ព្រះវិធូរបណ្ឌិតក្រាបទូលថា

កមណ្ឌលុំ គហេត្វាន, វង្កទណ្ឌញ្ច ព្រាហ្មណា;
បច្ចុបេស្សន្តិ រាជានោ, គាមេសុ និគមេសុ ច;
ជាទិន្នេ វុដ្ឋហិស្សាម, គាមម្ហិ វា វនម្ហិ វា។

*ព្រាហ្មណ៍ទាំងឡាយ កាន់កុណ្ឌីដាក់ទឹកផង ដំបងក្ងកផង ចូលទៅឯបអបនឹងស្តេចទាំងឡាយ ក្នុងស្រុកឬនិគម (ដោយគិតគ្នាថា) កាលបើគេមិនឲ្យ (វត្ថុអ្វីមួយ) ក្នុងស្រុកឬនិគម យើងនឹងមិនក្រោកឡើយ ។*

និគ្គាហកសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយ បុគ្គលរឹបជាន់ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះចាងកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហាប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យហើយ ចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

ព្រះវិធូរបណ្ឌិតក្រាបទូលថា

បរូឡ្ហកច្ឆនខលោមា, បង្កទន្តា រជស្សិរា;
ឱកិណ្ណា រជរេណូហិ, យាចកា វិចរន្តិ តេ។

ព្រាហ្មណ៍ទាំងឡាយនោះ មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល ពោយពាយដោយធូលីនិងលំអងដី ត្រាច់ទៅសូម (ទ្រព្យផ្សេងៗ) ។

ខាណុឃាតសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកដកនូវអង្កត់ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះ ព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ?

ព្រះបាទកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហប្ផលំ។

វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

ព្រះវិធុរបណ្ឌិតក្រាបទូលថា

ហារីតកំ អាមលកំ, អម្ពំ ជម្ពុំ វិភីតកំ,
លពុជំ ទន្តបោណានិ, ពេលុវា ពទរានិ ច។

*បពិត្រព្រះជនាធិបតី (ព្រាហ្មណ៍ទាំងឡាយ) ជួញសម៉ផង កន្ទួតព្រៃផង ស្វាយផង ព្រីងផង សម៉ពិភេកផង ខ្នុរសម្ងផង ឈើស្ទន់ផង ពោធផង ពុទ្រាផង ។*

រាជាយតនំ ឧច្ឆុបុដំ, ធូមនេត្តំ មធុអញ្ជនំ;
ឧច្ចាវចានិ បណិយានិ, វិបណេន្តិ ជនាធិប។

*ឈើកែសផង ទឹកអំពៅនិងស្ករអំពៅផង ខ្សៀផង ទឹកឃ្មុំនិងថ្នាំបន្តក់ភ្នែកផង ជួញ កណ្ឌៈមានតម្លៃតិច ឬមានតម្លៃច្រើនផង ។*

វាណិជកសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពាណិជ ហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះចាងកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ឧត្តិណំ សម្ម ឧស្សាម, យត្ថ ទិន្នំ មហប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

ព្រះវិធូរបណ្ឌិតក្រាបទូលថា

កសិវាណិជ្ជំ ការេន្តិ, បោសយន្តិ អជេឡកេ;
កុមារិយោ បវេច្ឆន្តិ, វិវាហន្តាវហន្តិ ច។

*(ព្រាហ្មណ៍ទាំងឡាយ) នាំគ្នាធ្វើនូវកសិកម្មនិងពាណិជ្ជកម្មផង ចិញ្ចឹមពពែនិងចៀមផង ទំនុកបម្រុងកុមារីផង រៀបចំអាពាហ៍ពិពាហ៍ផង ។*

សមា អម្ពដ្ឋវេស្សេហិ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយកុដុម្ពិកៈនិងគហបតី គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះចាងហោរព្យាកត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

ព្រះវិធូរបណ្ឌិតក្រាបទូលថា

និក្ខិត្តភិក្ខំ ភុញ្ជន្តិ, គាមេស្វេកេ បុរោហិតា;
ពហូ តេ បរិបុច្ឆន្តិ, អណ្ឌច្ឆេទា និលញ្ឆកា។

*មានព្រាហ្មណ៍ពួកខ្លះ ជាបុរោហិត (បរិភោគនូវភិក្ខាដែលគេទុកបម្រុងឲ្យខ្លួន) ពួកជនច្រើនគ្នា តែងសាកសួរព្រាហ្មណ៍នោះ ព្រាហ្មណ៍ទាំងនោះជាអ្នកក្រៀវពង (គោជាដើម) ផង ជាគ្រូសាក់ផង ។*

បសូបិ តត្ថ ហញ្ញន្តិ, មហឹសា សូករា អជា;

គោឃាតកសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*សម្លាប់សត្វចិញ្ចឹម គឺក្របី ជ្រូក និងពពែផង ក្នុងផ្ទះនោះ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលសម្លាប់គោ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះបាទកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

ព្រះវិធូរបណ្ឌិតក្រាបទូលថា

អសិចម្មំ គហេត្វាន,　　　　ខគ្គំ បគ្គយ្ហ ព្រាហ្មណា;
វេស្សបថេសុ តិដ្ឋន្តិ,　　　　សត្ថំ អព្ពាហយន្តិបិ។

*ព្រាហ្មណ៍ទាំងឡាយកាន់ដាវនិងខែល កាន់ព្រះខាន់ឈរ ឯបនៅក្បែរផ្លូវ ជាទីទៅនៃពួកឈ្មួញ នាំពួកឈ្មួញឲ្យផុត (អំពីពួកចោរ) ។*

សមា គោបនិសាទេហិ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អត្ថាតា តេ មហារាជ,　　　　តាទិសេ និបតាមសេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពួកជនអ្នកឃ្វាលគោ និងពួកអ្នកនេសាទ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះបាទកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស,　　　　សីលវន្តេ ពហុស្សុតេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតា មេថុនា ធម្មា,　　　　យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម,　　　　យត្ថ ទិន្នំ មហប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

ព្រះវិធុរបណ្ឌិតក្រាបទូលថា

អរញ្ញេ កុដិកំ កត្វា, កុដានិ ការយន្តិ តេ;
សសពិឡារេ ពាធេន្តិ, អាគោធា មច្ឆកច្ឆបំ។

*ព្រាហ្មណ៍ទាំងឡាយនោះ ធ្វើខ្ទមក្នុងព្រៃ ធ្វើអន្ទាក់វ័ធទាំងឡាយ បៀតបៀននូវទន្សាយ និងខ្លាត្រីផង នូវទន្សង ត្រី អណ្តើកផង ។*

តេ លុទ្ទកសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះប្រាកដស្មើដោយព្រានព្រៃ ព្រាហ្មណ៍ទាំងនោះ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះបាទកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

*ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។*

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហប្ផលំ។

*វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។*

ព្រះវិធុរបណ្ឌិតក្រាបទូលថា

អញ្ញេ ជនស្ស កាមា ហិ, ហេដ្ឋាមញ្ចេ បសក្កិតា;
រាជានោ ឧបរិ ង្ហាយន្តិ, សោមយាគេ ឧបដ្ឋិតេ។

*ព្រាហ្មណ៍ទាំងឡាយដទៃទៀតចង់បានទ្រព្យ ក៏ដេកខាងក្រោមគ្រែ កាលសោមយាគប្រាកដហើយ ស្តេចទាំងឡាយក៏ស្រង់ទឹក ពួដំខាងលើនៃគ្រែ ។*

មលមជ្ជកសមា រាជ, តេបិ វុច្ចន្តិ ព្រាហ្មណា;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកដុសក្អែល គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ?*

ព្រះបាទកោរព្យរាជត្រាស់ថា

អបេតា តេ ច ព្រហ្មញ្ញា, ន តេ វុច្ចន្តិ ព្រាហ្មណា;
អញ្ញេ វិធុរ បរិយេស, សីលវន្តេ ពហុស្សុតេ។

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត ។

វិរតេ មេថុនា ធម្មា, យេ មេ ភុញ្ជេយ្យុ ភោជនំ;
ទក្ខិណំ សម្ម ទស្សាម, យត្ថ ទិន្នំ មហប្ផលំ។

វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

ព្រះពោធិសត្វសម្តែងជនជាព្រាហ្មណ៍ខាងលើនេះ ត្រឹមតែវោហារប៉ុណ្ណោះ ឥឡូវនេះ កាលនឹងសម្តែងព្រាហ្មណ៍អ្នកមានប្រយោជន៍ដ៏ក្រៃលែង ទើបពោល ២ គាថាថា

អត្ថិ ខោ ព្រាហ្មណា ទេវ, សីលវន្តោ ពហុស្សុតា;
វិរតា មេថុនា ធម្មា, យេ តេ ភុញ្ជេយ្យុ ភោជនំ។

បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគភោជនរបស់ព្រះអង្គ ក៏មានដែរ ។

ឯកព្ភា ភត្តំ ភុញ្ជន្តិ, ន ច មជ្ជំ បិវន្តិ តេ;
អក្ខាតា តេ មហារាជ, តាទិសេ និបតាមសេ។

*ព្រាហ្មណ៍ទាំងនោះ បរិភោគនូវភត្តតែម្តង ទាំងមិនផឹកនូវទឹកស្រវឹង បពិត្រមហារាជ (ពួកព្រាហ្មណ៍នេះ) ខ្ញុំព្រះអង្គបានក្រាបទូលព្រះអង្គហើយ យើងនឹងចូលទៅអញ្ជើញពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ?*

*បណ្តាបទទាំងនោះ បទថា **អ្នកមានសីល** សេចក្តីថា ដល់ព្រមដោយអរិយសីល ។ បទថា **ជាពហុស្សូត** បានដល់ ដល់ព្រមដោយការចាក់ធ្លុះសច្ចៈដ៏ច្រើន ។ បទថា **ព្រាហ្មណ៍ប្រាកដដូច្នោះ** សេចក្តីថា ពួកយើងចូលទៅជិត ដើម្បីប្រយោជន៍ដល់ការនិមន្តព្រាហ្មណ៍ទាំងឡាយ ដែលជាព្រះបច្ចេកពុទ្ធ អ្នកមានបាបបន្សាត់បង់ហើយ ។*

*ព្រះរាជាស្តាប់កថា របស់ព្រះពោធិសត្វហើយ ត្រាស់សួរថា ម្នាលវិធុរៈសម្លាញ់ ព្រាហ្មណ៍ជាអគ្គទក្ខិណេយ្យបុគ្គល នៅក្នុងទីណា ? ព្រះពោធិសត្វទូលថា បពិត្រមហារាជ អគ្គទក្ខិណេយ្យព្រាហ្មណ៍នោះនៅនឹងញកភ្នំនន្ទមូលក៍ ក្នុងព្រៃហិមពាន្ត ទិសខាងជើង ។ ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ម្នាលបណ្ឌិត លោកចូរស្វែងរកព្រាហ្មណ៍ទាំងនោះ ដល់យើង ដោយកម្លាំងរបស់លោកចុះ ដូច្នេះកាលទ្រង់មានចិត្តត្រេកអរទើបត្រាស់ព្រះគាថាថា*

**ឯតេ ខោ ព្រាហ្មណា វិធុរ,　　សីលវន្តា ពហុស្សុតា;**
**ឯតេ វិធុរ បរិយេស,　　　　 ខិប្បញ្ច នេ និមន្តយ។**

*ម្នាលវិធូរៈ បើពួកព្រាហ្មណ៍នុ៎ះឯង ជាអ្នកមានសីល ជាពហុស្សូត ពិតមែន ម្នាលវិធូរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍នុ៎ះចុះ ចូរអញ្ជើញព្រាហ្មណ៍ទាំងនោះមកឆាប់ៗ ។*

*ព្រះមហាសត្វទទួលព្រះតម្រាស់របស់ព្រះរាជានោះថា ល្អ ហើយក្រាបទូលថា បពិត្រមហារាជ បើយ៉ាងនោះ សូមព្រះអង្គឲ្យរាជបុរសនាំស្គរត្រាច់ទៅ វាយប្រកាសថា ពួកអ្នកនគរចូរតាក់តែងនគរ ហើយនាំគ្នាឲ្យទាន អធិដ្ឋានឧបោសថ ចូរសមាទានសីលចុះ ហើយសូម*

ទ្រង់សមាទានឧបោសថ ជាមួយនឹងបរិជនរបស់ព្រះអង្គផង ។ ព្រះពោធិសត្វពោលដូច្នេះ ហើយ ខ្លួនឯងបរិភោគអាហារព្រឹក សមាទានឧបោសថ ក្នុងសាយណ្ហសម័យ ឲ្យមនុស្សនាំ ស្មុគមាសដែលពេញដោយជាតិបុប្ផា តម្កល់បញ្ច្រប្រតិស្ឋានជាមួយនឹងព្រះរាជា រឭកគុណ ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំ ក្រាបអារាធនានិមន្តដោយពាក្យថា **សូមព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដែលនៅនឹងញកភ្នំនន្ទមូលក៏ ក្នុងឧត្តរហិមវន្ត ចូរមកទទួលភិក្ខារបស់ពួកខ្ញុំ ក្នុងថ្ងៃស្អែកនេះ ចុះ** ដូច្នេះហើយក៏បាចផ្កាឈើ ៨ ក្ដាប់ ទៅលើអាកាស ។ ក្នុងពេលនោះ ព្រះបច្ចេកពុទ្ធ ទាំងឡាយ ៥០០ អង្គដែលនៅក្នុងទីនោះ ផ្កាឈើក៏ទៅ ហើយធ្លាក់ចុះលើព្រះបច្ចេកពុទ្ធទាំង នោះ ។ ព្រះបច្ចេកពុទ្ធកាលពិចារណា បានដឹងហេតុនោះហើយ ត្រាស់នឹងគ្នាថា ម្នាល មារិសៈទាំងឡាយ ពួកយើង គឺវិធុរបណ្ឌិតនិមន្តហើយ វិធុរបណ្ឌិតនោះ មិនមែនសត្វថោក ទាប លោកជាពុទ្ធង្កុរ[១] នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បនេះឯង ពួកយើងនឹងធ្វើការ សង្គ្រោះលោក ដូច្នេះហើយ ទើបទទួលនិមន្ត ។ ព្រះមហាសត្វដឹងភាពជាអ្នកទទួលនិមន្ត របស់ព្រះបច្ចេកពុទ្ធ ដោយសញ្ញាគឺការមិនត្រឡប់មកនៃផ្កាឈើ ហើយទូលព្រះរាជាថា បពិត្រមហារាជ ក្នុងថ្ងៃស្អែក ព្រះបច្ចេកពុទ្ធនឹងនិមន្តមក សូមព្រះអង្គធ្វើសក្ការៈចុះ ។

ក្នុងថ្ងៃស្អែក ព្រះរាជាធ្វើមហាសក្ការៈ ឲ្យតាក់តែងអាសនៈ ដែលមានតម្លៃថ្លៃ ក្នុងមហា ពេង ។ ព្រះបច្ចេកពុទ្ធទាំងឡាយជម្រះសរីរៈក្នុងស្រះអនោតត្តៈ កំណត់វេលាហើយ និមន្ត មកតាមផ្លូវអាកាស ចុះក្នុងព្រះលានហ្លួង ។ ព្រះរាជា និងព្រះពោធិសត្វមានចិត្តត្រេកអរ ទទួលបាត្រអំពីដៃព្រះបច្ចេកពុទ្ធ និមន្តឲ្យឡើងកាន់ប្រាសាទ ឲ្យគង់លើអាសនៈ ថ្វាយ

---

១. ពន្លកព្រះពុទ្ធ គឺព្រះពោធិសត្វដែលបម្រុងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលជាប្រាកដ ។

ទក្ខិណោទក[១] អង្គាសដោយខាទនីយៈ និងភោជនីយៈដ៏ប្រណីត ។ ក្នុងកាលព្រះបច្ចេកពុទ្ធធ្វើភត្តកិច្ចស្រេចហើយ ក៏និមន្តដើម្បីប្រយោជន៍ដល់ថ្ងៃស្អែក រហូតដល់ ៧ ថ្ងៃ ហើយបានថ្វាយមហាទាន ។ ក្នុងថ្ងៃទី ៧ ក៏ថ្វាយគ្រឿងបរិក្ខារទាំងពួង ។ ព្រះបច្ចេកពុទ្ធទាំងឡាយធ្វើការអនុមោទនា ហើយនិមន្តទៅវិញតាមផ្លូវអាកាស សូម្បីបរិក្ខារទាំងឡាយ ក៏អណ្ដែតទៅជាមួយនឹងព្រះបច្ចេកពុទ្ធនោះដែរ ។

ព្រះសាស្ដាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះបាទកោសល ដែលជាឧបដ្ឋាករបស់តថាគត បានថ្វាយ**វិចេយ្យទាន** (ទានដែលជ្រើសរើស) នោះ មិនជាអស្ចារ្យទេ បោរាណបណ្ឌិតទាំងឡាយ សូម្បីក្នុងកាលព្រះពុទ្ធមិនកើតឡើង ក៏បានថ្វាយវិចេយ្យទានដូចគ្នា ដូច្នេះហើយ ព្រះអង្គប្រជុំជាតកថា

**តទា រាជា អានន្ទោ អហោសិ** ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ

**វិធុរបណ្ឌិតោ បន អហមេវ អហោសឹ** ចំណែកវិធុរបណ្ឌិត គឺតថាគតនេះឯង។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដលេក ៦០ ទំព័រ ៤៨)

ថ្ងៃពុធ ២ កើត ខែជេស្ឋ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ១៦ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ.

---

១. ទឹកជាគ្រឿងចម្រើន គឺទឹកដែលប្រួចដាក់លើបាតដៃនៃបដិគ្គាហកបុគ្គល ក្នុងពេលដែលគេឲ្យទានរួចភ្លាមៗ : នៅពេលវេរឧបោសថាគារថ្មី ទាយកបានប្រួចទក្ខិណោទកលើហត្ថា នៃលោកចៅអធិការ។ អ្នកខ្លះហៅទក្ខិណោទក នេះថា ទក្សោទក អ្នកខ្លះថា ទឹកស្មោទក (--ទក់) ដោយហៅក្លាយពីសំស្ក្រឹតថា ទក្សិណោទក ។